# *សម្ភាសន៍ជាមួយឈ្មោះ ទុន វ៉ន ភេទស្រី អាយុ៦៧ឆ្នាំ*
## *មុខងារនៅសម័យខ្មែរក្រហមៈ ប្រធានក្រុមប្រមូលមាស*
## *សព្វថ្ងៃរស់នៅភូមិម៉ៅ ឃុំផ្អាវ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ*
## *ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១០*
## *សម្ភាសន៍ដោយៈ ហ៊ិន សុធានី*
## *០០:២៩:៣៧*
## *១៩ទំព័រ*

ធានី : ខ្ញុំមកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំចុះមកនេះគ្រាន់តែចង់សាកសួរលោកយាយ ទាក់ទងពីប្រវត្តិរបស់លោកយាយផ្ទាល់ ដែលបានឆ្លងកាត់តាំងពីមុនរហូតមកដល់ឥឡូវ ហើយថាលោកយាយបានជួបការលំបាកអីខ្លះ ពីសម័យមុនរហូតមកដល់ឥឡូវយាយ ។ ចា៎! ចង់ដឹងផង ហើយក៏ជាស្រុកកំណើតភូមិយើង?

វ៉ន : អឺ! ចឹងការលំបាក កាលហ្នឹងជួបពិបាកត្រឹមបដិវត្តស៊ីបាយមិនដែលឆ្អែត អត់មានបាយស៊ីស៊ីតែបបរទឹកលាយបន្លែ ណាអង្ករតែម៉ាកំប៉ុងឆ្នាំងប៉ុនណាណៃ ហូតតែទឹក ។ ហើយប្តីរកស៊ីធ្វើការខាងទន្លេត្រីនោះ ក៏មិនដែលហ៊ានយកមកឲ្យប្រពន្ធកូនស៊ី ។ ក៏លួចបើមកអាំងត្រីមួយប៉ុននេះចុះ គាស់គល់ស៊ីផាប់ម៉េចធ្វើម៉េចមិនចេះធុំ ស៊ីស្ងាត់ៗស៊ីទទេរ អត់បាយ បានបបរហូតទទេរ ត្រីស៊ីទទេរ ។ អូ! ផាប់ ។ កាលដែលនេះក៏ចាប់ ដល់នេះប្តីខ្ញុំឈប់ធ្វើត្រី ធ្វើខាងឈ្លបៗ...(ខ្យល់) ខ្ញុំកាលនោះខ្ញុំនៅក្មេង គេឲ្យធ្វើប្រធានៗដើរដកមាសពីគេ ក៏គេទាញអស់ខ្ញុំមិនបានយកស្អីហ្នឹងគេប៉ុនក្រចកទេ ខ្ញុំមិនដឹងគេថាយកធ្វើអី មិនល្អទេ គេថាយកទៅពាក់ឲ្យចង្កៀង គេឆ្លាតគេចេះយកដាក់គេបានចាយ ដល់មកដល់ចូលឯងក៏....។ ប្រមូលមាសនាងឯងមានមាសប៉ុន្មានៗប្រមូលអស់ ។ ហ៎! ម្ចាស់ដែលប្រមូលរើសយកអាណា ។ មានអាដុំប៉ុនបាតដៃ មានអាដុំវែងប៉ុនៗនេះ ប្រជាជនថ្មី ។ បើយកហើយពាក់ គេ...អាណាខ្សែខ្លួនវែងៗបើយកមិនឲ្យទុកទេ ឲ្យពាក់នឹង-ក បានមិនហ៊ានយកទេ ដាក់វិញទុកៗ ។ មិនដឹងគេយកទៅណា ប្រធានឃុំគេយកទៅណា ។

ធានី : ចឹងកាលអ៊ំ កាលពេលពាក់នឹង-កហ្នឹង មានគេដើរពាក់ចឹងដែរ?

វ៉ន : ទេ! អ្នកណាហ៊ានពាក់ ។

ធានី : ហេតុអី?

រ៉ែង ៖ ខ្លាចគេថាឯងកម្មសិទ្ធិ គេយកវែវចោលហើយ ។

ធានី ៖ អូ! តាមពិតគ្រាន់គេឲ្យរើសលេងទេ?

រ៉ែង ៖ ហ្នឹងហើយ ។

ធានី ៖ អត់មានអ្នកណាហ៊ានយកទេ?

រ៉ែង ៖ នោះហើយ គ្មានអ្នកណាហ៊ានយក គេជុំគ្នាគេ ហ៊ានយកលួកមាត់ពួកកាលនោះ គេយកដាក់ចង្កៀង ខ្លះគេយកចងជើងលេងថ្ងៃនេះ ល្ងាចឡើងគេយកដាក់ដោះទៅទុកណាទៅទុកណែដឹង ។ ខ្ញុំដល់នេះទៅបាត់ ដល់ចប់ទេបាត់មីនេះបាត់មីនោះ ដែលយើងត្រង់មិនបានប៉ះពាល់អ្នកណា ម៉ាខ្មែរ ម៉ាហុន ម៉ាជីអីក៏ ។

ធានី ៖ អត់អី ដល់ពេលអ្នកណាដែលប៉ះពាល់ខ្សែមាសខ្សែអីហ្នឹងស្លាប់ទាំងអស់?

រ៉ែង ៖ បាត់ៗស្លាប់ ។

ធានី ៖ ស្គាល់ឈ្មោះគាត់ទេ យាយកាលហ្នឹង?

រ៉ែង ៖ អ្នកណា ។

ធានី ៖ អ្នកដែលនៅក្រុមជាមួយយាយដែលដើរប្រមូលមាសជាមួយយាយហ្នឹង?

រ៉ែង ៖ នៅស្រុកទ្រាស ។

ធានី ៖ ហ្នឹងឈ្មោះអីគេទៅ?

រ៉ែង ៖ ងាប់អស់ហើយ ភ្លេចឈ្មោះអស់ហើយ ។

ធានី ៖ ដែលស្លាប់ ដែលយកមាសទៅ?

រ៉ែង ៖ ដឹងថាងាប់ ដឹងថាទៅណា ។ ចុះបើដូចម្សិលមិញចេះចុះ ដូចជា២-៣ថ្ងៃ ដឹងថាអង្គការគេប្រធានគេនាំទៅធ្វើការឯណា ដូចគេហៅក្បាលក្របី ត្រពាំងថ្ម ទៅលើកអាងលើអី ។ ខ្ញុំកូនងាំផង ឲ្យកិនស្រូវផង ដាំបាយ ។

ធានី ៖ ប៉ុន្តែយាយកាលហ្នឹង ដែលថាដំបូងម៉េចបាន ពេលបានយាយគេចាប់ផ្តើមប្រមូលមាសពីប្រជាជនថ្មី ។

រ៉ែង ៖ ប្រមូលតែរួចអស់ គេក៏ឈប់ រួចផ្លាស់ ។

ធានី ៖ ចឹងយាយធ្វើប្រធានប្រមូលនៅទ្រាសហ្នឹង?

រ៉ែង ៖ នៅទ្រាសហ្នឹង ។

ធានី ៖ នៅភូមិទ្រាស ឬក៏នៅក្នុងឃុំទ្រាស?

រ៉ែង ៖ ឃុំទ្រាស តាសៀវយើងហ្នឹង ។

ធានី ៖ ភូមិអីគេ?

រ៉ែង ៖ ភូមិទ្រាស ។

ធានី ៖ ឃុំអីគេ?

រ៉ែង ៖ ឃុំផ្តាំដែរតា សព្វថ្ងៃគេបំបែកមិនដឹងយ៉ាងណា ។

ធានី ៖ ហើយដល់ពេលហើយនៅកន្លែងភូមិហ្នឹងទៅដើរប្រមូល ។

រ៉ែង ៖ ប្តីខ្ញុំក៏ឈឺ ទៅនៅហ្នឹងផ្ទះអត់បានធ្វើការអី ទៅនៅតែខ្ញុំ ។

ធានី ៖ ចឹងកាលមុនដំបូងមក យាយបានគេឲ្យធ្វើប្រធានដើរប្រមូលមាស អ្នកណាគេអ្នកចាត់តាំងឲ្យយាយធ្វើ?

រ៉ែង ៖ ភូមិស្តី កម្មាភិបាល ។

ធានី ៖ ឈ្មោះអីគេកម្មាភិបាល?

រ៉ែង ៖ ភ្លេចអស់ហើយ ឈ្មោះតាស៊ូ តាអីណា ។

ធានី ៖ តាស៊ូហ្នឹងគាត់ជាអី ជាប្រធានសហករណ៍ ឬក៏កម្មាភិបាល គណៈអី?

រ៉ែង ៖ គណៈអី ភ្លេចអស់ហើយ ។

ធានី ៖ តាស៊ូហ្នឹង ប្រធានសហករណ៍ ឬយ៉ាងម៉េច ឬក៏គណៈឃុំ គណៈសង្កាត់អី?

រ៉ែង ៖ គណៈភូមិដឹង ខ្ញុំមិនសូវដឹងទេ មិនបានស្តាប់ ដល់កូនខ្ញុំគ្រាន់ចេះអង្គុយក៏ហើយខ្ញុំក៏គេដាក់ទិស ឲ្យទៅលើកអាងតាម៉េង ។

ធានី ៖ យាយទៅលើកអាងតាម៉េងដែរ?

រ៉ែង ៖ ទៅលើក កូនទាន់ចេះអង្គុយហើយ ដឹកអន្ទង់ឲ្យអង្គុយ ........តាមនេះអី.......កូនក្មេងរត់ថាហឺ!គេចង់បានតែខ្ញុំ ។ តែនេះហៅតែឈ្មោះខ្ញុំ......កម្លាំងមានចេះតែមានទៅ ស៊ីបបរទឹករលក ។

ធានី ៖ ចឹងកាលដំបូងហ្នឹង តាស៊ូហ្នឹងចាត់តាំងឲ្យអ៊ំហ្នឹង ទៅប្រមូលមាស?

រ៉ែង ៖ .........ពួកនិរតីមិន......... ។

ធានី ៖ អត់ទេ ចង់និយាយថាតាស៊ូ ដែលចាត់តាំងឲ្យយាយប្រមូលមាសដំបូងនោះ ឈ្មោះតាស៊ូ?

ប្តី ៖ នោះឯង បានពួកនិរតី ។

ធានី ៖ ហ្នឹងហើយតាស៊ូហើយ បាននិរតីមែនទេ?

រ៉ែង ៖ ហ្នឹងហើយ ។

ប្តី ៖ ហ្នឹងហើយ បាននិរតីធ្វើតែគ្នាគេ ។

ធានី : ប៉ុន្តែចង់និយាយថា ពេលគាស៊ូមកប្រមូលមាសហ្នឹងយកទៅណា អត់ដឹងទេ?

វ៉ង : មិនដឹងទេ ។

ធានី : មាសហ្នឹងបានប៉ុន្មានដែលមើលទៅ?

វ៉ង : មិនដឹងទេ ។

ធានី : ហើយប្រមូលពីប្រជាជនណាខ្លះ?

វ៉ង : មិនដឹងទេ ប្រមូលដូចនាផងឯងប្រធានដើរប្រមូលជាមួយប៉ុន្មាននាក់៨-១០ ប្រមូលម៉ាភូមិ ។

ធានី : ម៉ាភូមិៗទ្រាសហ្នឹង?

វ៉ង : ហ្នឹងហើយ ប្រមូលទៅ៨-១០នាក់ ។

ធានី : ចា៎! ប្រមូលហើយយកទៅឲ្យ?

វ៉ង : ហើយទៅម៉ាជួរត្រង់នេះ អញទៅត្រង់នេះ អាខ្លះទៅត្រង់នេះមកទាំងអស់គ្នា គ្រាន់ម៉ាដ្ឋិល ធំ ។

ធានី : មានជាអីខ្លះទៅ មានជាអីខ្លះ ជាខ្សែដៃ ខ្សែក ឬជាអី?

វ៉ង : ខ្សែដៃ ខ្សែក មាសដុំ ម៉ាសន្ទឹកប្រជាជនថ្មី ។

ធានី : មកពីណាវិញប្រជាជនថ្មីហ្នឹង?

វ៉ង : មកពីភ្នំពេញណាទេ អ្នកជម្លៀស មកកំប៉េច ។ ប្ដីខ្ញុំកាលនោះគេធ្វើឈ្លប ។ ខ្ញុំខ្សែកម៉ាខ្សែ ចិញ្ចៀន២វង់ អានេះមួយអារយ៉ៃ ។ *"នែក!កុំទុកណា"* ប្ដីខ្ញុំឃើញគេយកទៅវៃចោល បើ អានេះរកបានទៀត បើយើងរស់ ។

ធានី : អូ! គាត់និយាយចឹង?

វ៉ង : ហ្នឹងក៏ដោះឲ្យគេទាំងអស់ ជីវិតរស់នៅយើងអាចរកបាន ។

ធានី : ហើយកាលហ្នឹងប្ដីយាយឈ្មោះអីគេ?

វ៉ង : ឈ្មោះឡាម ។

ធានី : អីគេឡាម?

វ៉ង : ឡាច ឡាម ។

ធានី : ឡាច ឡាម ។ គាត់អ្នកធ្វើឈ្លប?

វ៉ង : ហ្នឹងហើយ ។

ធានី : ឈ្លបអីគេ ភូមិ ឬឈ្លបឃុំ?

វ៉ង : ឈ្លប ប្រជាជនណាដែលមិនបានស៊ីអី ណាក្បត់ ។

ធានី ៖ ប៉ុន្តែឈ្លបហ្នឹង គេធ្វើការនៅឃុំ ឬនៅភូមិយើង?

វ៉េង ៖ នៅហ្នឹងភូមិយើង ឈ្លបឃុបៗ ។

ធានី ៖ ឈ្លបភូមិ ចា៎!គាត់ហ្នឹងប្រធាន ឬក៏កូនចៅគេ?

វ៉េង ៖ ប្ដីខ្ញុំ ។

ធានី ៖ ចា៎!

វ៉េង ៖ ទេ! កូនចៅគេៗប្រើ ។

ធានី ៖ គេប្រើ ។ ហើយគាត់ដឹងថាមានគេឲ្យប្រមូលមាស យាយក៏ឲ្យប្រមូលមាសយកទៅឲ្យគេទាំងអស់គ្នាចឹងទៅ?

វ៉េង ៖ ហ្នឹងហើយ របស់ឯងក៏មិនហ៊ានទុកៗខ្លាចគេយកទៅវ៉ៃចោល ប៉ុនមិនទៅសួរឯងថា "*មាសឯងមិនដាក់ទេ ទុក ដល់គេទៅសួរ*" ដែលមិនដឹង នាងឯងនៅផ្ទះជិតខ្ញុំ ខ្ញុំនៅបៀតនាងឯង ខ្ញុំទិញខ្សែកម៉ាខ្សែនាងឯងមិនដឹង ខ្ញុំទិញស្ពឺក៏នាងឯងនៅបៀតគ្នា ។

ធានី ៖ ចឹងខ្លាចដែរ?

វ៉េង ៖ នោះហើយ ។

ធានី ៖ ហើយដល់ប្រមូលទៀតទៅ?

វ៉េង ៖ ត្រូវតែ អញដឹងហើយមីនោះមានខ្សែក២-៣ខែ ២ខែ គេយកក៏បាន ថាមិនឃើញគ្រប់អាហ្នឹងយកពីណា អានោះវាផុតទៅ វាអត់បានរឿងទេ ។

ធានី ៖ ហើយបន្ទាប់មកទៀត ម៉េចទៀតយាយក្រោយពីធ្វើការប្រមូលមាសហ្នឹង យាយធ្វើអីទៀត?

វ៉េង ៖ ខ្ញុំឈឺ ដេកឡើង ខ្ញុំឈឺឡើងដេកពេទ្យសង្គមកិច្ច ។

ធានី ៖ ឈឺអីគេ?

វ៉េង ៖ ឈឺគ្រុនស្ដីចុះអាចម៍យ៉ាងណា ស្គមៗបាយវាមិនដែលមានបាយស៊ី "*នាងអើយ*"ហ៊ានហៅពេទ្យថ្ងៃនោះ យ៉ាប់ខ្លាំង ជុះអាចម៍សុទ្ធតែទឹកអស់ជាតិទឹកបាយក៏មិនមានម៉ាគ្រាប់ ជួនពេទ្យគេដើរបៀតចេះ ពេទ្យសង្គមកិច្ចគេ "*នាងអើយនាងបែកថ្នាំឲ្យអញរាប់ៗ*" ។ ទៅពេទ្យគេមកពីថ្មពួក ពេទ្យគ្នាគេមកពីថ្មពួក សុំៗចឹងដូចគ្រាប់ថ្នាំប៉ុននេះ ទន់ល្អៗវែងប៉ុននេះវែងជាង… គេឲ្យមក "*លេបទៅ*" ម៉ាសន្ទុះវាឡើងមកចេះ……ដល់នេះល្ហើយភ្នែកបើកស្រឡះ អរគុណពេទ្យស្រុកសព្វថ្ងៃ ជួន ។

ធានី ៖ ឈ្មោះអីគេ?

រ៉ង ៖ ដួន ។

ធានី ៖ គាត់ហ្នឹងធ្វើពេទ្យ?

រ៉ង ៖ ហ្នឹងហើយ ។ នាងអើយសព្វថ្ងៃអញគ្មានអីសងគុណឯងទេ បានថ្នាំម៉ាគ្រាប់ប៉ុនហ្នឹងទេ ។

ធានី ៖ ហើយដួនហ្នឹង សព្វថ្ងៃគាត់នៅរស់នៅភូមិយើដែរ?

រ៉ង ៖ នៅរស់ ។

ធានី ៖ នៅភូមិយើង?

រ៉ង ៖ នៅភូមិអំពិល ។

ធានី ៖ ភូមិអីគេ?

រ៉ង ៖ ស្រុកអំពិល ។

ធានី ៖ ស្រុកអំពិល ភូមិអំពិល?

ប្ដី ៖ ភូមិអំពិល ។

ធានី ៖ ភូមិអីគេតា?

ប្ដី ៖ ឃុំនេះឯង ឃុំផ្គាំ ។

ធានី ៖ ភូមិៗ?

ប្ដី ៖ ភូមិអំពិល ។

ធានី ៖ ហើយដល់ពេលដួនហ្នឹង អ្នកជួយយាយឲ្យថ្នាំពេទ្យ?

រ៉ង ៖ នោះហើយទៅដល់ អូ!ម៉េចបានបាយស៊ីអូ!... គេយកកូនចានតូចប៉ុននេះ គេដាក់កំពូលទឹកស្ករម៉ាស្លាបព្រា អញថា ដួនអើយ អញរស់ហើយ ដែលប្រាប់ពេទ្យ បានបាយស៊ីតិច រស់មែនទែន គេដួសឲ្យ គេដាំដែលពេទ្យដែលមក... គេដួសយកមកម៉ាកូនចាន ទឹកស្ករម៉ាស្លាបព្រា គេយកស្ករខ្មែរយើង មិនមែនស្ករស ។ និយាយឆ្ងាញ់ណាស់(សើច) វាឃ្លានពេកលិតចាន ដួនអើយ ម៉េចបានទៀតធ្វើឲ្យបានទៀត ។

ធានី ៖ គេឲ្យ?

រ៉ង ៖ គេឲ្យកន្ទះអានោះទៀតដែលមានកម្លាំងជាង ដួនហើយចាំអញដាទៅផ្ទះបាន អញឲ្យមាន់ឯងមួយ ឲ្យមួយខ្សឹបៗទេ ។

ធានី ៖ គាត់ប្រុស?

រ៉ង ៖ ស្រី ។

ធានី ៖ អូ! ស្រី?

រ៉េង ៖ ហ្នឹងហើយ ខ្ញុំទៅដេកតែសន្តមកិច្ចយូរគ្រាន់ បើលើកដីតាម៉េងស្គាល់ហើយ ។

ធានី ៖ ចាំ!

រ៉េង ៖ តាម៉េងលើករួច មិនដែលកើតអីសោះ ក្តាមដីកកប់សំបក ។

ធានី ៖ ចឹងលោកយាយកាលពេលគេងពេទ្យហ្នឹង គេប៉ុន្មាន?

រ៉េង ៖ ហាំ!

ធានី ៖ គេងពេទ្យហ្នឹងគេងប៉ុន្មានថ្ងៃ?

រ៉េង ៖ អឺ! គ្នាម៉ាខែជាងដែរហ្នឹង ។

ធានី ៖ អូ! រយៈពេលម៉ាខែជា?

រ៉េង ៖ អឺ! ស៊ីតែដើមចេក ។

ធានី ៖ បន្ទាប់មកទៀតលើកអាងតាម៉េងហ្នឹង?

រ៉េង ៖ ចាំ! លើកឡើងរួច ។

ធានី ៖ ហូបតែក្តាមខ្យង លួចហូប?

រ៉េង ៖ ទេ! វាដីកឃើញ ដែលគាស់ដីទៅបែកស៊ីទាំងស្នូកទាំងអីមិនសល់ទេ ឲ្យធ្វើម៉េចឲ្យតែមានចូល គ្រពះរវល់ ។

ធានី ៖ អឺ!ចឹងយាយដំបូងយាយថាទៅប្រមូលមាស ដល់ពេលប្រមូលមាសហើយទៅសម្រាកពេទ្យ ដល់ពេលជិតឈឺហើយ?

រ៉េង ៖ ចាំ!

ធានី ៖ អាហ្នឹងឈឺអីគេ យាយដឹងទេ យាយដឹង?

រ៉េង ៖ ឈឺអីប្រាប់មិនត្រូវ ស្គមៗ ។

ធានី ៖ ម៉េចទៀតយាយ?

រ៉េង ៖ ស្គមៗក៏វាគ្រុន វាដើរមិនកើត គ្មានឈឺគ្មានស្នាមអីទេ ។

ធានី ៖ តែមានហូបអីគ្រប់គ្រាន់ទេៗ?

រ៉េង ៖ មានអីហូបគ្រប់គ្រាន់ហ្នឹងនោះឯងហ្នឹងបានវាយ៉ាប់ ។

ធានី ៖ ចឹងបានកាលពេលប្រមូលមាសហើយ ក៏អត់មានអីហូបដែរ?

រ៉េង ៖ ប្រមូលដឹងគេយកទៅណាអស់រលីង ដឹងគេយកទៅណា ឲ្យឯងដឹងយកទៅទុកធ្វើកេរ្តិ៍ខ្ទួនវាក៏ មិនដឹង ។

ធានី ៖ ហើយចឹងក៏អត់អីហូបក៏ឈឺៗសម្រាកពេទ្យ៣ខែ?

រ៉ន ៈ មានប្រាក់ណា ដែលមានស្ទីទិញគ្មានស្ទីលក់ ។

ធានី ៈ ចាំ! ដល់ពេលសម្រាកពេទ្យ៣ខែ ហើយបានយាយគេឲ្យទៅលើកអាផ?

រ៉ន ៈ លើកអាផ ។

ធានី ៈ ចុះដែលថាធ្វើត្រីជាមួយប្តីគយាយ ពេលណា?

រ៉ន ៈ ត្រី ។

ធានី ៈ ធ្វើត្រី?

រ៉ន ៈ ប្តីខ្ញុំ ។

ធានី ៈ ប្តីយាយធ្វើត្រី ប៉ុន្តែយាយអ្នកមកលើកអាផទេ អត់បានធ្វើត្រីជាមួយគាត់ទេ?

រ៉ន ៈ អានេះខែប្រូតទេ ខែនេះបានធ្វើត្រី ខែវស្សានៅផ្ទះ ។

ធានី ៈ ខែវស្សានៅផ្ទះ?

រ៉ន ៈ ខែវស្សាគេឲ្យជញ្ជូនដី កាប់បន្ទ្រានខែត្រធ្វើដីក ។

ធានី ៈ ធ្វើអីហើយ ទៅធ្វើត្រីដែរ?

រ៉ន ៈ ទេ!

ធានី ៈ ដល់ពេលខែប្រាំងបាន?

រ៉ន ៈ ទេ! គេធ្វើត្រីគេអ្នកធ្វើតែប្រុសៗ ។

ធានី ៈ តែគេយកឲ្យយាយហូប គាត់យកឲ្យយាយហូប?

រ៉ន ៈ ទេ! បើដឹងគេប្រូតតាមក្រុមចេះ ក៏ហ្នឹងអាចេះ ពួកខ្ញុំអ្នកធ្វើប្រធានខាងប្រូតចេះ ។

ធានី ៈ យាយប្រធានប្រូត?

រ៉ន ៈ ព្រឹកឡើងទៅនៅចាំកន្លែងនេះ ដាក់ចៀលមួយប៉ុននេះចែវទូកយកមកឲ្យ ។

ធានី ៈ ចឹងខែវស្សាយាយលើក ធ្វើអ្នកប្រូត?

រ៉ន ៈ ខែវស្សាធ្វើស្ទូង ដក ។

ធានី ៈ ស្ទូង ដក ហើយហ្នឹងធ្វើដី ដាក់ដីរោយដី?

រ៉ន ៈ ដែលឯងបានស្រួលក៏ ។

ធានី ៈ ប៉ុន្តែយាយធ្វើប្រធានគេ?

រ៉ន ៈ ស្ទូងមិនរួច ប្រធានម្តងៗតិចៗ ។

ធានី ៈ ប្រធានអ្នកប្រូត ប្រធានប្រូត?

រ៉ន ៈ ប្រធានប្រូត គេឲ្យដាំបាយ ។

ធានី ៖ ប្រធានក្រុម ឬប្រធានអីយាយ?

រ៉េង ៖ ប្រធានក្រុម ។

ធានី ៖ ប្រធានក្រុមច្រូត?

រ៉េង ៖ ចា៎!

ធានី ៖ មានគ្នាប៉ុន្មានទៅ?

រ៉េង ៖ ជួនណាទៅ៣០នាក់ ។

ធានី ៖ ក្រុមតូចគ្នា៣០នាក់ ។ ហើយចឹងយាយជាអ្នកប្រធានក្រុមចឹង ជួនកាលឆ្លៀតពេលដាំបាយ ដាំបាយឲ្យ?

រ៉េង ៖ ជួនណាគេដាក់ទិសឲ្យដាំបាយម្តង ម៉ាខែ កន្លះខែ ។

ធានី ៖ ដាំបាយឬដឹកនាំច្រូតចឹងទៅ?

រ៉េង ៖ រៀបចន្ទុរទូកទៅបេះព្រលិតទៅស្រុកស្តីនោះ យកមកបបរលាយ មិនឃើញគ្រាប់អង្ករណា តិច ។

ធានី ៖ ម៉េចក៏ចឹងយាយ ហេតុអីយាយអ្នកដាំបាយចឹង ដឹងថាហេតុអីបានអង្ករគេឲ្យម៉ាតិច?

រ៉េង ៖ បបរម៉ាក្រុមឲ្យ៥កំប៉ុង ម៉ាក្រុមតិចណាស់ហ៎ា ។

ធានី ៖ ហើយបើកពីណាវិញអង្ករហ្នឹង?

រ៉េង ៖ បើកពីប្រធានធំគេ អ្នកកាន់ក្តាប់ខាងអង្ករស្រូវ ។

ធានី ៖ ហេតុអីបានគេឲ្យតែ៥កំប៉ុងហើយយើងធ្វើការហត់?

រ៉េង ៖ វាមិនមានៗអង្ករយកស្រូវទៅណាអស់ ។

ធានី ៖ តែអង្ករយើងធ្វើបានទេ ប៉ុន្តែអត់មានអង្ករហូប?

រ៉េង ៖ អង្ករគេកិនព្រឹកឡើងគេបើកឲ្យ ។

ធានី ៖ ចង់និយាយថាស្រូវ មិញយាយថាយើងច្រូតស្រូវច្រូតអីមាន ដល់ពេល?

រ៉េង ៖ កាលនោះវាសំបូរតិច ដល់ស្រូវចូលជង្រុក ។

ធានី ៖ អស់បណ្តោយ?

រ៉េង ៖ ឡានមកដឹកៗ មិនដឹងទៅណា ។

ធានី ៖ ឡានដឹកទៅអត់មានអីហូបពេលខែប្រាំង?

រ៉េង ៖ អស់រលីង អស់ជង្រុករលីង អត់មានអីហូប ជង្រុកទទេរ ។

ធានី ៖ ចឹងដល់ពេលខែប្រាំងទៅដឹកប្រឡាយនៅអាងតាម៉េង?

រ៉េង ៈ ចា៎!

ធានី ៈ ជីកប្រឡាយនៅអាងតាម៉េងអត់មានអីហូបទេ ហើយយាយអ្នកធ្វើប្រធានដែរ?

រ៉េង ៈ ហូបបបរម៉ាខែគេឲ្យបាយរឹងម្តងៗ ទេ! ខ្ញុំអត់ធ្វើប្រធានទេៗ

ធានី ៈ ពេលនៅអាងតាម៉េងអត់ធ្វើប្រធានទេ?

រ៉េង ៈ ទេ!

ធានី ៈ ចា៎! ធម្មតាកូនក្រុមគេ?

រ៉េង ៈ កាលដើមដែលខ្ញុំនៅខាងនេះ ខ្ញុំកាលនោះខ្ញុំបានរត់ទៅខាងនោះហ្នឹងគេ ខ្ញុំរត់ទៅនេះ ចូលបានដល់គេវៃបានដល់ខាងនោះ ខ្ញុំបរទេះវង់ៗមកដេកហ្នឹងភ្នំដ្ដាំបានម៉ាយប់ ២យប់ក៏គេហៅចូលស្រុកៗ

ធានី ៈ ពេលយួនចូលហ្នឹងយាយ វៃគ្នាពេលយួនចូលហ្នឹង?

រ៉េង ៈ ហ្នឹងហើយ ដេកហ្នឹងព្រៃបាន២-៣យប់ ក៏យួនចូលក៏គេហៅចូលស្រុកវិញ មកដល់ទំនប់ខាងនោះៗ

ធានី ៈ ចឹងម៉េចបានជួបលោកតា?

ប្ដី ៈ ...ប្ដីវាងាប់មកស្រុកវិញៗ

រ៉េង ៈ ខ្ញុំស្រុកនៅនេះពីដើមមិញ ទៅនៅតាមប្ដីនោះៗ

ធានី ៈ តែប្ដីលោកយាយស្លាប់ដោយសារអីគេ?

រ៉េង ៈ ឈឺរបេងៗ

ធានី ៈ ឈឺរបេង ហើយចឹងរៀបគ្រួសារជាមួយលោកតាពេលឆ្នាំប៉ុន្មានទៅ?

រ៉េង ៈ ដឹងឆ្នាំប៉ុន្មាន កំពុងអាសង្គ្រាមនោះៗ

ធានី ៈ សង្គ្រាមយួនហ្នឹង?

ប្ដី ៈ កាលបានខ្ញុំនៅតែមានឡើងមក វាមិនទាន់ខ្មែរក្រហមមិនទាន់អស់ៗ

រ៉េង ៈ កំពុងតែបាញ់គ្នាពាសណាពាសណៃៗ

ធានី ៈ ហើយមានប៉ុារ៉ាមានអីចូលទេ?

រ៉េង ៈ ទើបមានៗចូលទេ ពុកតែដំណឹង ចូលដែរៗ

ធានី ៈ តែមានតែខ្មែរក្រហម ហើយហ្នឹងយួន?

រ៉េង ៈ តែចូលម៉ាភ្លែតៗ គេថាហ៎!ខ្មែរក្រហមដើរទ័ពមកហើយផ្អើលរត់ទៅៗ

ធានី ៈ រត់ទៅ ដល់ពេលប៉ារ៉ាមករត់ដែរ?

វ៉ន : ប៉ាភ័រត់ ពួកខ្មែរក្រហមចូលមកសួររកប៉ាភ៉ាទៅអស់ហើយ ។ មួយសន្ទុះតាមគ្នាទៀត ។

ធានី : ចឹងយាយហើយនឹងលោកតា រៀបការហើយបានកូនប៉ុន្មាននាក់?

វ៉ន : អត់មានទេ ។

ធានី : អត់មានកូនទេ?

វ៉ន : ចាំ!

ធានី : លោកតាមានកូនៗមុន កូនប្រពន្ធ?

វ៉ន : កូនប្រពន្ធ ខ្ញុំកូនប្រពន្ធមុន ប្ដីមុន ។

ប្ដី : វាក៏មានខាងកូនវា ។

ធានី : ចឹងយាយឈ្មោះអីគេ?

វ៉ន : ឈ្មោះវ៉ន ។

ធានី : អីគេវ៉ន?

វ៉ន : ឪ ។

ធានី : អូន?

វ៉ន : ទុន វ៉ន ។

ធានី : ទុន វ៉ន? ឆ្នាំហ្នឹងយាយអាយុប៉ុន្មានហើយយាយ?

វ៉ន : ឆ្នាំមមែអាយុប៉ុន្មាន៦៦ ៦៧ ។

ធានី : ៦៧ ឆ្នាំមមែ?

វ៉ន : ៦៨ មិនដឹងរាប់ ។

ធានី : យាយមានស្រុកកំណើតនៅណា?

វ៉ន : ស្រុកកំណើតខ្ញុំនេះហើយ ។

ធានី : ស្រុកកំណើតនៅភូមិអីគេហ្នឹងហៅភូមិអី?

វ៉ន : ភូមិម៉ៅ ។

ធានី : ឃុំផ្ដាំ ស្រុកអីគេ?

វ៉ន : ស្រុកស្វាយ ។

ធានី : ឪពុកយាយឈ្មោះអីគេ?

វ៉ន : ឪខ្ញុំ?

ធានី : ចាំ!

វ៉ន ៖ ឈ្មោះតាទុន ។

ធានី ៖ អីគេទុន?

វ៉ន ៖ ប្រពន្ធគាត់ទៀត យាយ ។

ធានី ៖ ចា៎! យាយឈ្មោះអីគេ?

វ៉ន ៖ ហ៊ុនដូចគ្នា បៀតគ្នា ។

ធានី ៖ ឈ្មោះអីគេ?

វ៉ន ៖ ឈ្មោះ ហ៊ុន, ទុន ។

ធានី ៖ គាត់ស្លាប់ហើយ?

វ៉ន ៖ អូ! ស្លាប់ពីកាលនោះសង្គមមុន ។

ធានី ៖ ដោយសារអីគេយាយ ដោយសារឈឺ?

វ៉ន ៖ មិនដឹងទេ ខ្ញុំ ។

ធានី ៖ បងប្អូនយាយមានប៉ុន្មាននាក់?

វ៉ន ៖ បងប្អូនខ្ញុំនោះ ។

ធានី ៖ ចា៎!

វ៉ន ៖ ងាប់អស់ហើយ នៅតែខ្ញុំ ។

ធានី ៖ ហ្នឹងហើយប៉ុន្តែមានប៉ុន្មាននាក់ បងប្អូនយាយ?

វ៉ន ៖ ប៉ុន្មានតា? ១បូ ២តាម៉ុក ៣បងខ្វាក់ ៤បងបូក ៥សាមុ ៦ខ្ញុំ នោះឯង ។

ធានី ៖ ៦?

វ៉ន ៖ ៦ ។

ធានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

វ៉ន ៖ ស្រី១ ២ហ្នឹងខ្ញុំ ។

ធានី ៖ ស្រី២ ប្រុស៤ នៅសល់តែយាយម្នាក់ទេ?

វ៉ន ៖ នោះ គេទៅអស់ហើយបងៗ ។

ធានី ៖ ស្លាប់ដោយសារអី?

វ៉ន ៖ បងខ្ញុំធ្វើមេឃុំគេបាញ់ មុនដំបូង ។

ធានី ៖ ចឹងបងមេឃុំហ្នឹងឈ្មោះអីគេ?

វ៉ន ៖ ឈ្មោះសាមុ ។

ធានី ៖ បងស្រី បងប្រុស?

រ៉ែង ៖ ប្រុស ។

ធានី ៖ បងប្រុសឈ្មោះអីគេ សាមុ?

រ៉ែង ៖ ទុនឪទុកដូចគ្នា បង ។

ធានី ៖ ទុន សាមុហ្នឹង ជាមេឃុំអីគេ មេឃុំផ្កាំយើង?

រ៉ែង ៖ ឃុំផ្កាំ ។

ធានី ៖ មេឃុំផ្កាំ ហើយត្រូវខ្មែរក្រហមបាញ់សម្លាប់?

រ៉ែង ៖ នោះហើយ ។

ធានី ៖ បាញ់សម្លាប់ ពេលចូលមក?

រ៉ែង ៖ ក៏គេចូលមក គាត់ប្រៀបហើយក៏ខឹង គាត់និយាយមុន និយាយគ្នារាល់ថ្ងៃ ។

ធានី ៖ ចឹងស្លាប់តែគាត់ម្នាក់ឯងទេ?

រ៉ែង ៖ ស្លាប់តិចណាស់ ជំទុកលេខ១ ជំទុកលេខ២ ជំទុកលេខប៉ុន្មាន រើសមកតំរៀបហ្នឹងខាងត្បូងភូមិ ។

ធានី ៖ ចឹងអ្នកធ្វើការនៅក្នុងឃុំភូមិហ្នឹងស្លាប់ទាំងអស់ប៉ុន្មាននាក់ ដឹងទេ?

ប្តី ៖ ទេ! ធ្វើតែបាញ់អ្នកធ្វើការ ។

ធានី ៖ ចា៎!ធ្វើការហ្នឹងប៉ុន្មាននាក់ យាយចាំទេ?

រ៉ែង ៖ មិនដឹងប៉ុន្មាន ខ្ញុំនៅទ្រាស ។

ធានី ៖ ចុះបងប្អូនយាយផ្សេងទៀត គឺស្លាប់ដោយសារគាត់ដែរ ឬក៏ស្លាប់ផ្សេងទៀត?

រ៉ែង ៖ សាមុនោះ ។

ធានី ៖ ក្រៅពីសាមុនោះ?

រ៉ែង ៖ អាបង១ងាប់ដោយសារជម្ងឺ ។

ធានី ៖ ផ្សេង១ទៀតស្លាប់ដោយសារជម្ងឺ ចឹងបងសាមុហ្នឹងគេបាញ់សម្លាប់រួមទាំងអ្នកធ្វើការនៅក្នុងឃុំហ្នឹងដែរ?

រ៉ែង ៖ ហ្នឹងហើយ ឲ្យឡើងមកគ្នាគេចុះគេចទៅឯលិចហ្នឹង ...ស្រែពេញស្រែវាលណា ទៅរកឃើញបាញ់នោះ ។

ធានី ៖ អូ! រត់ដែរ?

រ៉ែង ៖ រត់ហើយ ។

ធានី ៖ ហើយបងប្អូនផ្សេងទៀតស្លាប់ដោយសារជម្ងឺ?

រ៉េង ៖ គាត់មិនបានដឹងទេ កូនមួយ កូនតូចប៉ុននេះ តាមម៉ែឪ ពួនដំបូកបាំងចេះ គេដើរមកខាងនេះ គេដាក់ចំកណ្ដាលក្បាលបែក ដល់កូននោះចង់ដើង ។

ធានី ៖ អូ!ស្លាប់ទាំងអស់?

រ៉េង ៖ កូននោះឲ្យរត់ឃើញគេដើរអើងខាងនោះ គេបាញ់ភ្លើងសញ្ញាក៏ថាភ្លឺឃើញគេដើរអើងក៏រត់ទៅរកគេក៏ប្រាប់គេ ពុកខ្ញុំងាប់ហើយៗ ។ ដំបូកខាងលិចភូមិនេះ ខាងលិចភូមិផ្គាំ ។

ធានី ៖ ហើយដឹងអ្នកណាគេអ្នកស្លាប់គាត់ទេ ខ្មែរក្រហមហ្នឹងឈ្មោះអី បានសម្លាប់គាត់?

រ៉េង ៖ ម៉េចដឹង ខ្ញុំនៅទ្រាស ដែលគេហៅមក ។

ធានី ៖ យាយចឹងដំបូងពេលដែលយាយនៅទ្រាសហ្នឹង នៅជាមួយគ្រួសារអ្នកនេសាទ ហើយយាយអ្នកដើរប្រមូលយកមាសគេតាមផ្ទះហ្នឹងទៅ?

រ៉េង ៖ ពីដើមមិញ កាលដើម ។

ធានី ៖ ចា៎!ពីដើមមិញ បន្ទាប់មកទៀតបានយាយគេឲ្យមកធ្វើអាង នៅជីកអាងតាម៉េង ហើយដល់ពេលខែវស្សាឲ្យធ្វើស្អីគេ ។

រ៉េង ៖ អ្នកស្ទូង ។

ធានី ៖ ស្ទូងហ្នឹងហើយ ប្រធានស្ទូងប្រធានអីចឹងយាយនោះ?

រ៉េង ៖ ដកសំណាបទៅ.... ។

ធានី ៖ ក្រៅពីហ្នឹងយាយមានអីចង់បន្ថែមទៀតទេ?

រ៉េង ៖ មានស្អី ។

ធានី ៖ សួរខ្ញុំ ឆ្ងាញ់អីសួរ?

រ៉េង ៖ សួរស្អីខ្លះអី ។

ធានី ៖ ចឹងយាយចៅសុំយករឿងរ៉ាវដែលយាយប្រាប់ទាំងប៉ុន្មាន សុំយកធ្វើជាសៀវភៅក៏ដូចជាទុកឲ្យក្មេងៗនិងអ្នកស្រាវជ្រាវផ្សេង យកទៅស្រាវជ្រាវ ។

រ៉េង ៖ យកទៅស្ដី?

ធានី ៖ រឿងរ៉ាវដែលយាយប្រាប់ខ្ញុំមិញហ្នឹង ខ្ញុំនឹងយកទៅធ្វើជាសៀវភៅអីចឹង តើយាយអនុញ្ញាតិឲ្យខ្ញុំយកទៅជាចឹងអត់ ដូចយាយប្រាប់មិញចឹង ថាមានការសម្លាប់បង មានការស្ទូងអី មានការហូបអីពិបាកអីចឹង ។ សុំយករឿងរ៉ាវដែលយាយប្រាប់មិញហ្នឹង កត់ដៃហ្នឹង ។

រ៉េង ៖ សួរសព្វចឹង បានអំណោយអីខ្លះ គ្រាន់?

ធានី ៈ អត់មានទេ យាយ ព្រោះពួកខ្ញុំខាងអង្គការអត់មាន ដូចថាអត់មានលុយមានអីទេ ។

វ៉ែង ៈ អង្គការហ្នឹង គ្រាន់បានបើកលុយឲ្យខ្លះ ។

ធានី ៈ អត់មានទេយាយ ព្រោះពួកខ្ញុំចុះមកគឺជាការស្ម័គ្រចិត្តណា៎យាយ ។

វ៉ែង ៈ យកឈ្មោះ...គេឡើងមកដេញដោលឯងគេយកទៅវ៉ៃចោលណា៎ ។

ធានី ៈ អត់មានផង ព្រោះសម័យឥឡូវគេមានច្បាប់មានអីចឹង អត់អាចធ្វើទៅកើតទេយាយ ។

វ៉ែង ៈ ភ័យដឹងនិយាយរួច ចុងក្រោយគេហៅឈ្មោះវាវ១ ទៅណាដាក់ខ្សែភ្លើង ។

ធានី ៈ បើថាហៅទៅលេងភ្នំពេញប្រហែលជាអាចមាន ប៉ុន្តែថាហៅទៅធ្វើចឹងអត់មានទេយាយ ។ ចឹងខ្ញុំសុំថតរូប ក៏ដូចជាថតជាសម្លេងយាយបានអត់យាយ?

វ៉ែង ៈ ថតច្រើនតើ?

ធានី ៈ ចា៎!

វ៉ែង ៈ ទេនៅស្រុកនេះ?

ធានី ៈ ចា៎! ធ្វើទាំងអស់ចា៎!

វ៉ែង ៈ គ្រប់ផ្ទះ?

ធានី ៈ ឲ្យតែអ្នកមានប្រវត្តិរឿងរ៉ាវលំបាក ។

វ៉ែង ៈ គេប្រាប់ដូចខ្ញុំដែរ?

ធានី ៈ ចា៎!

វ៉ែង ៈ កុហកដឹង?

ធានី ៈ អត់កុហកទេ យាយ នេះម៉ាគំនរ ។

វ៉ែង ៈ ពិសោធន៍មើលឯណាដែលឈ្មោះគេ ។

ធានី ៈ មានម៉ាគំនរ តាំងពីព្រឹកមក ហើយមានអ្នកផ្សេងទៀត ដែលគាត់រង់ចាំខ្ញុំ ។ សូម្បីតែពូអីជិតុក ពូអីក្រុមប្រឹក្សាឃុំនេះ ក៏គាត់នៅដែរ ខ្ញុំជួបជាមួយគាត់ច្រើនដងហើយ អ្នកផ្សេង១ម៉ាគំនរ ។

វ៉ែង ៈ ពូអីមិនស្គាល់ឈ្មោះ មិនបានកត់ឈ្មោះគេទេ?

ធានី ៈ អឺ! ខ្ញុំមិនមែនអត់កត់ទេ ព្រោះខ្ញុំមិនអ្នកសម្ភាសន៍គាត់ ចឹងខ្ញុំអត់ដឹងឈ្មោះទេ អ្នកផ្សេង១ទៀត ដែលខ្ញុំសម្ភាសន៍បានខ្ញុំដឹង ។

វ៉ែង ៈ ចុះប្រុស១ដែលមកដុំ?

ធានី ៈ ប្រុស១គាត់សម្ភាសន៍ផ្សេងម៉េចខ្ញុំដឹង ។

រ៉ង ៖ សួរដូចគ្នាចឹង?

ធានី ៖ ចាំ! សួរដូចគ្នា សួររឿងរ៉ាវប្រវត្តិសម័យខ្មែរក្រហមម៉េចៗ ។ ចាំ! អរគុណយាយច្រើនដែលបានឲ្យខ្ញុំសម្ភាសន៍ ចាំ!អរគុណច្រើន ។

«ចប់»